# បច្ចុប្បន្នភាព

## ការធ្វើអនុលោមភាព និងការអនុវត្ត

# នៃបទដ្ឋានគតិយុត្តិស្តីពីភាគព្វកិច្ចគណនេយ្យ
# និងសវនកម្ម

បទបង្ហាញៈ លោក រី សុវណ្ណា
ប្រធានផ្នែកគោលនយោបាយ ច្បាប់ និងការតស៊ូមតិ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០២១

# កម្មវត្ថុ

- ធ្វើបច្ចុប្បន្នភាពនៃការធ្វើអនុលោមភាពនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- ការចូលរួមរបស់សង្គមស៊ីវិលដើម្បីពង្រឹងចំណងសាមគ្គីភាពនៃសង្គមស៊ីវិលក្នុងបេសកម្មបន្តបម្រើឧត្តមប្រយោជន៍ប្រជាពលរដ្ឋក្នុងស្ថានភាពរាតត្បាតនៃជំងឺកូវីដ ១៩ និងការតស៊ូមតិរួមគ្នា ។

# កាលប្បវត្តិនៃកាតព្វកិច្ចគណនេយ្យ និងសវនកម្ម និង
# បទប្បញ្ញត្តិពាក់ព័ន្ធនានាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

| បទប្បញ្ញត្តិពាក់ព័ន្ធ | កាលបរិច្ឆេទ | ស្ថានភាព |
|---|---|---|
| ច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម - កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ - កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារជាធរមាន - កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ២០១៦ | ពន្យាការអនុវត្ត |
| អនុក្រឹត្យលេខ ស្ដីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើស ច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម | ២០២០ | ពន្យាការអនុវត្ត |
| ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីដាក់ឱ្យអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត ០១ | ២០១៨ | ពន្យាការអនុវត្ត |
| ប្រមូលធាតុចូលដើម្បីធ្វើឱ្យល្អប្រសើរឡើងនូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត ២ | ... | កំពុងប្រមូលធាតុចូល និងពិភាក្សាសម្រេចកម្រិតបច្ចេកទេស |

# ការប្រឈមនៃការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធនានាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

| ការអនុវត្តកាតព្វកិច្ច | ការប្រឈម |
|---|---|
| កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ | បញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុត្រូវធ្វើជាភាសាខ្មែរ និងបង្ហាញជាប្រាក់រៀល<br>ការិយបរិច្ឆេទគណនេយ្យ មិនស្របគ្នានឹងបរិច្ឆេទបិទបញ្ជីដែលកំណត់នៅក្នុងច្បាប់នៅថ្ងៃទី ៣១ ធ្នូ<br>របាយការណ៍ហិរញ្ញវត្ថុត្រូវធ្វើឱ្យរួចរាល់ក្នុងរយៈពេល ០៣ ខែ ក្រោយកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ |
| កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារជាធរមាន<br>*ភាគច្រើនសង្គមស៊ីវិលនៅកម្ពុជាប្រើ Modified Cash Basis មូលដ្ឋានបង្គរសាច់ប្រាក់* | *ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត (មូលដ្ឋានសាច់ប្រាក់) (CFRS for NFPE) សាមញ្ញជាងគេ*<br>*ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម (CIFRS for SME)*<br>*ស្តង់ដារាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) - ស្តង់ដាធំ (Full Options)* |
| កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ចំណាយប្រចាំឆ្នាំសរុបពី ២ ប៊ីលានរៀល (៥០ ម៉ឺនដុល្លារ) និង ចំនួនកម្មករនិយោជិតចាប់ពី ២០ នាក់ឡើងទៅ |

# បទអន្តរាគមន៍នៃអង្គការសង្គមស៊ីវិល

| បទអន្តរាគមន៍ | ការកត់សម្គាល់ |
|---|---|
| ប្រមូលធាតុចូល - ក្រុមការងារហិរញ្ញវត្ថុ - ក្រុមការងារពន្ធដារ - ក្រុមហ៊ុនសវនកម្ម - សមាជិក - ដៃគូអភិវឌ្ឍន៍ | ជុំរុញការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងការអនុវត្តច្បាប់<br><br>ការអនុវត្តកាតព្វកិច្ចនានាតាមច្បាប់គណនេយ្យ និងសវនកម្ម និងពិន័យអន្តរការណ៍មិនអាចពន្យាទៀតបានទេ |
| សិក្ខាសាលារវាងអង្គការសង្គមស៊ីវិល និងនិយ័តករគណនេយ្យ និងសវនកម្ម | |
| ការដាក់ធាតុចូលដោយផ្ទាល់ និងលាយលក្ខណ៍អក្សរ | |
| កិច្ចពិភាក្សាជាន់ខ្ពស់រវាងថ្នាក់ដឹកនាំនៃនិយ័តករគណនេយ្យ និងសវនកម្ម និងតំណាងអង្គការសង្គមស៊ីវិល | |

# ការឆ្លើយតប - កាតព្វកិច្ចគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធនានាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

| ការប្រឈម | ការឆ្លើយតប |
| --- | --- |
| *កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ*<br><br>បញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុត្រូវធ្វើជាភាសាខ្មែរ និងបង្ហាញជាប្រាក់រៀល<br><br>ការិយបរិច្ឆេទគណនេយ្យ មិនស្របគ្នានឹងបរិច្ឆេទបិទបញ្ជីដែលកំណត់នៅក្នុងច្បាប់នៅថ្ងៃទី ៣១ ធ្នូ<br><br>របាយការណ៍ហិរញ្ញវត្ថុត្រូវធ្វើឱ្យរួចរាល់ក្នុងរយៈពេល ០៣ ខែ ក្រោយកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ | *និយ័តករគណនេយ្យ និងសវនកម្មនឹងរៀបចំសារាចរណែនាំ ដោយផ្តល់ការអនុគ្រោះដល់អង្គការ ឬសមាគម ប្រើភាសាអង់គ្លេសក្នុងការរៀបចំបញ្ជីគណនេយ្យ និង កត់ត្រាចំណាយ (ប្រើប្រព័ន្ធកុំព្យូទ័រ Accounting Software) ប៉ុន្តែរបាយការណ៍ហិរញ្ញវត្ថុត្រូវផលិតជាភាសាខ្មែរ ព្រោះមិនស្មុគស្មាញ ស្ថាប័នអាចបកប្រែដោយខ្លួនឯងបាន ។ អង្គការ សមាគម អាចបំប្លែងរបាយការណ៍ហិរញ្ញវត្ថុពីលុយដុល្លារ (រូបិយប័ណ្ណមុខងារ) ទៅជាប្រាក់រៀល (រូបិយប័ណ្ណបង្ហាញ) ទៅតាមអត្រាប្តូរប្រាក់ផ្លូវការដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។* |

# ការឆ្លើយតប - ភាតព្វកិច្ចគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធនានាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

| ការប្រឈម | ការឆ្លើយតប |
| --- | --- |
| *កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារជាធរមាន*<br>ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត (មូលដ្ឋានសាច់ប្រាក់) (CFRS for NFPE) សាមញ្ញជាងគេ<br>ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម (CIFRS for SME)<br>ស្តង់ដារាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) - ស្តង់ដាធំ (Full Options) | លើកទឹកចិត្តឱ្យអង្គការ ឬសមាគមប្រើប្រាស់ស្តង់ដាងាយ ប្រើស្តង់ដាណាមួយក៏បានដែរ ប៉ុន្តែអង្គការសង្គមស៊ីវិលមានជម្រើសប្រសិនខ្លួនមានសមត្ថភាពធ្វើអនុលោមភាពស្តង់ដាដទៃ (ប្រើ ២ ស្តង់ដា) ដោយការជូនដំណឹងដោយមិនចាំបាច់រង់ចាំការឆ្លើយតបដល់ ឬ ពី និយ័តករគណនេយ្យ និងសវនកម្ម ។ ស្តង់ដាទាំងនេះអាចរកបាននៅក្នុងគេហទំព័រនៃនិយ័តករគណនេយ្យ និងសវនកម្ម ។<br><br>និយ័តករបានកត់ត្រាទុកនូវស្ថានភាពជាក់ស្តែង *Modified Cash Basis មូលដ្ឋានបង្គរសាច់ប្រាក់ ដើម្បីស្វែងរកដំណោះស្រាយកម្រិតបច្ចេកទេស* |

# ការឆ្លើយតប - កាតព្វកិច្ចគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធនានាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

| ការប្រឈម | ការឆ្លើយតប |
|---|---|
| កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ<br><br>ចំណាយប្រចាំឆ្នាំសរុបពី ២ ប៊ីលានរៀល (៥០ ម៉ឺនដុល្លារ) និង ចំនួនកម្មករនិយោជិតចាប់ពី ២០ នាក់ឡើងទៅ | ការដាក់របាយការណ៍សវនកម្មរបស់ស្ថាប័នទាំងមូល - អង្គការសង្គមស៊ីវិលបំពេញគ្រប់លក្ខខណ្ឌ - ត្រូវរកសវនករឯករាជ្យមកធ្វើសវនកម្ម ។ បើមិនជាប់លក្ខខណ្ឌច្បាប់មិនតម្រូវទេ តែអាចធ្វើដោយស្ម័គ្រចិត្ត ។ (១៥ កក្កដា នៃឆ្នាំបន្ទាប់ ក្រោយការបិទបញ្ជី )<br><br>របាយការណ៍សវនកម្ម ត្រូវធ្វើដោយក្រុមហ៊ុន ដែលទទួលស្គាល់ដោយនិយ័តករគណនេយ្យ និងសវនកម្ម (មាននៅក្នុងគេហទំព័រផ្លូវការ និងហ្វេសប៊ុក) ។ ជាការកំណត់ដោយច្បាប់ក្រុមហ៊ុនសវនកម្មត្រូវសរសេរសង្ខេបនូវការវាយតម្លៃរបស់ខ្លួនជាភាសាខ្មែរ ។<br><br>និយ័តករគណនេយ្យ និងសវនកម្មទទួលយកការព្រួយបារម្ភរបស់អង្គការសង្គមស៊ីវិលស្តីពីការចំណាយថ្លៃលើសេវាកម្មសវនកម្ម ។ |

# បច្ចុប្បន្នភាពនៃភាតព្វកិច្ចគណនេយ្យ និងសវនកម្ម និង
# បទប្បញ្ញត្តិពាក់ព័ន្ធនានាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

| បទប្បញ្ញត្តិពាក់ព័ន្ធ | កាលបរិច្ឆេទ | ស្ថានភាព | បច្ចុប្បន្នភាព | ជំហ៊ានបន្ទាប់ |
|---|---|---|---|---|
| ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម - កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ - កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារជាធរមាន - កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ២០១៦ | ពន្យាការអនុវត្ត | រក្សាស្ថានភាពដដែល | ការធ្វើអនុលោមភាព (ត្រៀម) |
| អនុក្រឹត្យលេខ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម | ២០២០ | ពន្យាការអនុវត្ត | រក្សាស្ថានភាពដដែល | ការធ្វើអនុលោមភាព (ត្រៀម)<br><br>បន្តកិច្ចពិភាក្សាលើមាត្រា ០៦ នៃអនុក្រឹត្យ |

# បន្ទាប់៖ សំណើរ និងសំណូមពរ

1. ផ្តល់ពេលវេលាគ្រប់គ្រាន់ដល់អង្គការ សមាគមដើម្បីកសាងសមត្ថភាពធនធានមនុស្ស និងថវិកាក្នុងការលើកកម្ពស់ការធ្វើអនុលោមភាពកាតព្វកិច្ចគណនេយ្យ និងសវនកម្ម យ៉ាងហោចណាស់ ០១ ឆ្នាំមុន ។
2. លើកកម្ពស់ការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលធនធានមនុស្សដោយឥតគិតថ្លៃ ឬការឧបត្ថម្ភធនធានឱ្យបានទូលំទូលាយដល់អង្គការសមាគមដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាស្តីពីកាតព្វកិច្ចគណនេយ្យ និងសវនកម្ម ។
3. បន្តទទួលយកធាតុចូល និងបន្តផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយជុំវិញការអនុវត្ត ការប្រឈម និងវឌ្ឍនភាពនៃការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម ។

# សូមអរគុណ...